# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ជួប សាម៉ៃ

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ជួប សាម៉ៃ

## <u>ការសង្ខេបរបស់អ្នកមីង ជួប សាម៉ៃ</u>

អ្នកមីងជួប សាម៉ៃ ពេញមួយជីវិតគាត់មានជីវិតដែលមិនជាស្រួលប៉ុន្មានទេ ។ជីវិតអ្នកមីងពុំសូវបានរៀនសូត្រច្រើនប៉ុន្មានទេ ព្រោះដោយសាររកស៊ីចិញ្ចឹមម្តាយនឹងប្អូន ហើយនៅក្នុងរបបសង្គ្រាមគឺគាត់ជាកុមារដើររើសអាចមន៍គោ ទូលអាចមន៍ ហើយហូបបាយរួម តែគាត់សំណាងដោយសារនៅតំបន់ដែលគាត់រស់នៅគឺបានបាយហូបហើយគាត់អាចសុំយកទៅអោយម្តាយហូបនៅមន្ទីរពេទ្យបានទៀត ហើយប្អូនម្តាយរបស់គាត់ឆ្លងទន្លេនៅសម័យប៉ុលពត ហើយឪពុកគឺត្រូវបានគេសម្លាប់នៅក្នុងសម័យនោះ ។ នៅក្នុងជំនាន់លន់ នល់ គាត់ក៏បានគេចគ្រាប់ហើយដោយសារនៅក្មេង គាត់មិនសូវធ្លាប់ឃើញពីមុនមកគាត់គិតថាល្អមើល តែដល់ពេលឃើញគេយំហើយភ័យគាត់ក៏កើតដឹងថាគួរអោយខ្លាច។ បន្ទាប់ពីបែកប៉ុលពតអ្នកមីងរកស៊ីបេះត្រកួនលក់ ហើយក៏រៀបការមានស្វាមីហើយប្រកបរបររនេសាទដើម្បីចិញ្ចឹមកូន។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍នៅក្នុងខែមិនាឆ្នាំ២០១៨ ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា អ៊ីចឹងញ៉ុមនឹងសួរសំនួរអ្នកមីងបន្ថែមទៀតអំពីជីវិតអ្នកមីងបន្ថែមទៀតថាអ្នកមីងឆ្លងកាត់រឿងអីគេខ្លះនៅក្នុងជីវិតតែមុននឹងចូលដល់ប្រវត្តិនៃសង្គ្រាមទាំងមូល ចង់ដឹងអំពីការសិក្សាអ្នកមីងជាមុនសិន មីងឥឡូវប្រាប់ឈ្មោះពេញរបស់អ្នកមីងជាមុនសិន។

ខៈ ញ៉ុមឈ្មោះ ជួប សាម៉ៃ។

ក៖ មីងបានរៀនទេ?រៀនបានថ្នាក់ទីប៉ុន្មានវិញ?

ខ៖ បានថ្នាក់ទី៣។

ក៖ ល្អហើយអីចឹងគ្រាន់បើហើយអីចឹង។

ខ៖ ថ្នាក់ទី៣ឥឡូវហាំ!!

ក៖ ចាំ!!មិនមែនជំនាន់មុនទេអីចឹងហេ??

ខ៖ ហ្នឹងហើយ។

ក៖ បើសិនជាជំនាន់មុនឡូយម៉ង។

ខ៖ ៧៩(១៩៧៩)បានថ្នាក់ទី១ ៨៣(១៩៨៣)។

ក៖ ឈប់រៀនទៅ?

ខ៖ ឈប់រៀនទៅចុះបើម៉ែប្អូននៅតូចបានអ្នកណារកចិញ្ចឹម វាមិនកាប់អំពៅ
ទៅធ្វើខ្ញុំគេ។ក៖ចាំ!!ខ៖ ទំរាំប្អូនធំ!!

ក៖ មីងពេលរៀនហ្នឹងរៀននៅសាលាបឋមសិក្សាណាវិញ?

ខ៖ ហ៊ីសាលាចាប់ឆាយហ្នឹង។

ក៖ ម៉េចទៅមីង?

ខ៖ ម្ដងគេអោយទៅណេះម្ដងគេអោយទៅណោះ!!ម្ដងដើរទៅដល់សិត្បូ ម្ដងដើរទៅត្រឹមនេះ
ហ្នំគេត្រូវចិត្តអោយ!! អត់ដែលទៅតាខ្មៅទេ អាសាលាសាមគ្គីនេះ សាលាផ្ទះយាយញឹបនេះ
សាលាកន្លែងនៅជិតផ្ទះមីងញ៉ុមណោះ ដល់តែប្រលងដើរទៅដល់ដើមរកោហ្នំ!!

ក៖ ដើមរកោហ្នឹងនៅឯណាមីង?

ខ៖ ជិតសិត្បូហ្នំ!!!

ក៖ ឆ្ងាយណាស់!!

ខ៖ ហ៊ីដើរតាំងពីរម៉ោងទំរាំតែដើរដល់។

ក៖ហើយអត់មានកង់អត់មានអីជិះទេពេលហ្នឹង?

ខ៖ អត់ទេ ។

ក៖ ហេតុតែស្រលាញ់ការសិក្សាពេកលះបង់ខ្លាំងណាស់!!!

ខ៖ ទៅប្រលងបាន កាលហ្នឹងបានរង្វាន់បានសៀវភៅ៣ក្បាលប៊ិចមួយដើម ដែកខ្មៅមួយដើម ជរ័លុបមួយដុំ ជាប់លេខ២ ហ្ហ៎!!គ្រូអរជិតស្លាប់
ហើយដល់រៀនៗទៅស្រលាញ់ពួកម៉ាកជាងសិក្សាទៀតគេគ្រូថាគេឡើងថ្នាក់ទៅម៉ែហី? ញ៉ុមអត់ឡើងទេអ្នកគ្រូញ៉ុមនឹកពួកម៉ាក់ញ៉ុមណាស់!!

ក៖ចំ!!

ខ៖ នៅចាំគេ ចាំៗៗអីចាំម្លេ៎ះថ្នាក់ទីមួយថ្នាក់ទីពីរ
ថ្នាក់ទីមួយថ្នាក់ទីពីរចូលដល់ថ្នាក់ទី៣នឹកឃើញអានិតម៉ែ។

ក៖ តែឪុបប៉ុន្មានឆ្នាំបានអើរបានផុតលែងនឹកពួកម៉ាក់បានឡើងថ្នាក់នេះ ប៉ុន្មានឆ្នាំ?

ខ៖ ហ៊ីអត់ដឹងឪុបប៉ុន្មានឆ្នាំទេ!!

ក៖យូរហេ?

ខ៖ គ្រាន់តែបែកភ្លាមចូលរៀនភ្លាម ពី៧៩(១៩៧៩) ដល់៨៣(១៩៨៣)
គិតមើលទៅ?នៅតែថ្នាក់ទី២ហ្នឹង។

ក៖ចា៎!!!

ខ៖ ហើយឪុបមួយឆ្នាំ។

ក៖ឪុបមួយឆ្នាំអីវ៉ាន់ទេ!!អត់សួរច្រើនប៉ុន្មានទេ ។

ខ៖ ហើយគ្រូធ្វើអី ចង់ធ្វើអី?សួរញ៉ុមចង់ធ្វើអីញ៉ុមចង់ធ្វើពេទ្យ។

ក៖ហ្ហ៎ៗ!!

ខ៖ ហើយចង់ធ្វើពេទ្យនឹកឃើញ នឹកឃើញខ្មាសខ្លួនទៀតហាំ!!ហោចង់ធ្វើពេទ្យ។

ក៖ ហោមីងបើពេលហ្នឹងបើនៅរៀនដល់នេះហាំ
ដល់ចប់មកមីងបានធ្វើហាំ!!រៀនសុទ្ធតែលេខ២ហើយតែគ្រាន់តែយ៉ាប់មួយគឺនៅថាចាំពួកម៉ាក់
។

ក៖ជាប់លេខអត់បានលេខមួយទេលេខ២លេខ៣លេខ២លេខ៣
ប្រលងខែណាពេលណាក៏ដោយប៉ុន្តែថាគេក្រោយឯងហាំ !!ទៅព្រុយៗ
គ្រូអោយឡើងហ៊ីញ៉ុមអត់ទៅទេមីង!!ហ៊ីដល់តែថ្ងៃដំបូង
ទៅរៀនដំបូងមានអីគ្រូវ៉ៃញ៉ុមបាន១០គេបាន១០អត់វ៉ៃវ៉ៃញ៉ុម។

ក៖ ហ៊ីម៉េចបានវ៉ៃ?

ខ៖ យើងអោយគេមើល មានអីវ៉ៃញ៉ុមជេរម៉ែគ្រូ ញ៉ុមឈប់រៀន ហែកសៀវភៅចោលខ្ទេច។

ក៖ចំ!!

ខ៖ ហែកសៀវភៅហ្នឹងចោលខ្ទេចហើយជេរម៉ែគ្រូហើយហើយឈប់រៀនតែម្តង ។

ក៖ចំ!!

ខ៖ ដល់តែទ្រាញ៉ុមថាអញ្ចេក
ទៅសុំអោយគ្រូអោយញ៉ុមទៅរៀនហ្នឹងហើយអោយតែឃើញមុខញ៉ុម
ហ៊ីម៉េចប៉ុណ្ណឹងទេក៏ញ៉េញម្លេះ
ញ៉ុមថាចុះលោកគ្រូឯងវ៉ៃញ៉ុមធ្វើអី?គេអត់វ៉ៃទៅវ៉ៃតែញ៉ុមញ៉ុមបាន១០ដែរ ជេរម៉ែគ្រូជេររហូត
ដល់ជួបគាត់ហាំ!!គាត់ថាអញ្ចេកអើរមីមេជេរ ជួបគាត់ពេលណាក៏គាត់ថា។

ក៖ចំលែកណាស់មីងណោះ!!អ៊ីចឹងក្តីស្រម៉ៃរបស់អ្នកមីងនៅពីទូចចង់ធ្វើជាគ្រូពេទ្យមីងណោះ?

ខ៖ ហ៊ីចង់ធ្វើពេទ្យដល់នឹកឃើញ ហ៊ីខ្លួនអត់ចង់ធ្វើពេទ្យ។

ក៖ចាំ!!

ខ៖
ហើយពួកម៉ាក់ញ៉ុមគេសុទ្ធតែធ្វើពេទ្យនៅតាខ្មៅហ្នុ៎!!បើកហាងបើកអីនៅតាខ្មៅអីអស់ហើយ។

ក៖ចាំ!!

ខ៖ ឥឡូវថាម៉ែគេទៅនៅអាមេរិកអស់ហើយ ពួកម៉ាក់ញ៉ុមវាទៅអាមេរិកអស់ហើយ។

ក៖ មីងបើនៅរៀនអនាគតមិនធម្មតាទេតែនៅចាំគេហើយនឹងមិនព្រមរៀនត
តែមកពីលំបាកជីវភាពដែរ!!

ខ៖
ទៅរៀនចេញពីរៀនវិញជួយណាលអត់បាយទេរត់ទៅបេះត្រកួនណោះនៅទួលក្រសាំងហ្នុ៎!!
ដើរទេណាស់ ដើរមកទួលត្រកួនតាមទំនប់ទៀតហ្នឹងហា៎!!!ឈប់៤
៥ដងបានដល់ផ្ទះផ្ទះនៅមុខឈប់ហ្នឹងម្តងទៅនៅហ្នឹងដល់ទៅដើរទៅដល់មុខទៀត
ដើរងើបម៉ោង១ម៉ោង២ទៅតាខ្មៅទៀត មកពីតាខ្មៅវិញមុជទឹកទៅរៀន
ចេញពីរៀនវិញបាយម៉ែទុកអោយ ក៏ទុកទៅ ជូនណាលអោយម៉ែវិចទៅជាមួយ
ម៉ែម៉ែឯងវេចទៅមុន ជូនណាលទៅដល់គេឡើងហើយ ឡើងមកវិញហើយ
ទៅញ៉រទទាតម៉េចៗក៏ដោយអោយតែបានមួយបាច់មកផ្ទះវិញមកដល់ចងហើយម៉ោង១ម៉ោង
២អីមកដល់ផ្ទះវិញហើយក៏មានដែរម៉ោង!!ជូនណាលចាស់ៗគាត់មមើរគាត់ក៏មិនដឹងអាមាន់រ
ងាវម៉ោង១០អីវ៉ាន់ហ្នឹងគាត់ហៅទៅដែរហ្នឹងហើយចេះតែទៅតាមគាត់ទៅ
អាណាទៅដេកកណ្តាលផ្លូវតាមថ្នល់ហ្នឹងដាក់ត្រកួនមួយបាច់ប៉ុននេះទៅ
ដាក់ទៅគុមអឺចឹងទៅបាស់ដៃបាស់ជើងនៅហ្នឹងហើយ
គាត់ថាដេកហ្នុ៎ចាំអញដាស់អាហ្នឹងដេកមើលតែគាត់មើលរើយមក យាយអើយជួយលើក
ចាស់ៗហ្នឹងជួយលើកហើយ ដល់តែហើយលើកទៅ
ជូនណាលមកវិញមកវិញមកផ្ទះដេកអស់ចិត្តទៅ ភ្លឺអត់ទាន់ភ្លឺផងហ្នឹង។

ក៖ ចាញ់បោកចាស់!!ហ៊ីចាញ់បោកមាន់ មាន់រងាវម៉េចក៏ចេះតែទៅដែរ
អត់មានមើលម៉ោងមើលអីទេពេលហ្នឹង?

ខ៖ មានម៉ោងមានអីរកតែបាយហូបមិនចង់បានផងម៉ែ!!
ជូនណាលណោះគេធ្វើស្រូវអញ្ចឹងហើយយើងមាននេះណាយើងមានកំលាំងណា
គេមិនយកដីអស់ទៅគេចែកតែគ្នាគេមានគោមានក្របីទៅ គេធ្វើគ្នាគេ

គេធ្វើស្រូវហើយយើងចាំតែបោសបាតវាអង្គុយមកផ្ចិតអាជើងមុង មុងពីដើមហ្ន៎!!យកមករលាស់រលាស់វេទនាណាស់។

ក៖ មីងពិបាកយូរហើយ ពិបាកពិបាកទៅអោយតែមានការសប្បាយចិត្ត។ឥឡូវអ្នកមីងឥឡូវចូលដល់គ្រួសារវិញ អ្នកមីងរៀបការជាមួយពូនៅឆ្នាំណាវិញ?

ខ៖ ៨៤(១៩៨៤)

ក៖ ១៩៨៤។ ចាំ!!មីងរៀបការជាមួយពូត្រូវបានបង្ខិតបង្ខំដោយឪពុកម្តាយឬក៏ស្រលាញ់គ្នាដោយចិត្តខ្លួនឯង?មើលនិយាយប្រវត្តិស្នេហាតិចមើលម៉េចបានជួបគ្នា?

ខ៖ ហេគាត់ធ្វើទាហានគាត់មកញ៉ែរញ៉ុមតើ!!ដោយសារប៊ិគក់មួយដុំ។

ក៖ ដោយសារប៊ិគក់មួយដុំហេ?

ខ៖ ហ្នឹងហើយដោយសារប៊ិគក់មួយដុំ។

ក៖មើលម៉េចបានមានប្រវត្តិដោយសារប៊ិគក់មួយដុំបានកើតជាស្នេហានេះ?

ខ៖ ទៅមើល ទៅមើលអើយកាលហ្នឹងមើលល្ខោន។

ក៖ចាំ!!

ខ៖ហេគាត់មិនមែនអោយញ៉ុមដល់ដៃទេណាស់ គាត់ណោះនៅអង្គុយទេណាណោះ គាត់ហុចតាមគេបណ្តោះញ៉ុមសួរញ៉ុមហៅគាត់តែម៉ែម៉ែនោះ មានអីម៉ែៗម៉ែបានប៊ិគក់ពីណាមក?គាត់បួចមាត់ថាហ្ន៎អាពូនោះតើហា!!

ក៖ ហេគេស្រលាញ់ហើយហេ?

ខ៖ អត់ទេ អត់ស្គាល់មុខគេច្បាស់ផងហ្នឹង គេតាមមកដល់ផ្ទះ តាមមកដល់ផ្ទះគេជក់បារីញ៉ុមឃើញថាអញ្ចេក ហ៊ីពូពូឯងមកធ្វើអី? ដល់ហើយញ៉ុមមកលេងផ្ទះបងឯងតើ!!

កះហើយម៉េចទៀតមឹង?

ខះ ដល់ហើយយើងស្រលាញ់គ្នាទេ ចាស់ៗនេះអោយទៅ ការអោយទៅរៀបអោយទៅ។

កះហ្ហ៎អ៊ីចឹងក៏ចូលស្ដីដណ្ដឹងអោយទៅមឹងណោះ?

ខះ ហ្នឹងហើយ ។

កះ ហើយមឹងពេលចូលស្ដីដណ្ដឹងហ្នឹងគេមានអោយជំនូនអីទេខាងប្រុស?

ខះ
ហ៊ីថ្លៃជំនូនអីកុំអោយតែគេអុកឡុកទៅកុំអោយតែក្នុងបន្ទាយគេអត់ការអោយទៅ។កះចា៎!!ខះ
ព្រោះអីទាហានគេត្រូវចេញបេសកម្មហ្នឹងហា៎!!គេមិនអោយយកគ្រួសារផងហ្នឹង។

កះហ្ហ៎!អ៊ីចឹងពូជាទាហាន?

ខះ ហ្នឹងហើយ!!

កះ ហើយអើរពេលហ្នឹងដោយសារចេញពីនេះហី ចេញពី!!

ខះ ពីសាលា!!

កះហើយមឹងពេលរៀបការជាមួយពូមានចេញទៅសមរភូមិអីទៀតទេ?

ខះ ទៅទៀតស៊ីឈ្នួលគេ ។

កះហ្ហ៎!!

ខះ មានកូនមួយទៅស៊ីឈ្នួលគេបាន៣០០០។

កះ ស៊ីឈ្នួលអីគេ?

ខះ ស៊ីឈ្នួលឡើងលក់ជីវិតហ្នឹង!!

កះ ធ្វើទាហានឡើងវ៉ែ?

ខះ ៣ខែ!!ស៊ីឈ្នួលគេ។

កៈហ្ហ៎យកដាក់ជីវិតទៅម៉ង?

ខៈ ហ្នឹងហើយ ហើយប្រធានភូមិប្រធានឃុំនៅណោះអើយគេទ្រាំទ្រាំទៅគេដឹងយើង!!

កៈ ហើយប៉ុន្មានឆ្នាំបានពូឈប់ធ្វើទាហានបាននៅជាមួយជាប់នៅជាមួយមីងរហូត?

ខៈ ទៅអាហ្នឹងស៊ីឈ្នួលគេហ្នឹងកាលប៉ុន្មានបីខែហ្នឹងឈប់រហូតទៅ។

កៈ
ចាំ!!អញ្ចឹងមីងសំរាប់អើរពីពេលដែលមីងរៀបការជាមួយលោកពូមកកូនប៉ុន្មាននាក់សរុបទាំងអស់?

ខៈ កូន៦។

កៈ៦នាក់??

ខៈ ហ្នឹងហើយ។

កៈ តែមុនហ្នឹងពូប្រាប់ញ៉ុមថា៨!!៨ឬក៏៦ពូ?

ខៈ ហ្ហ៎ហ្នឹងអ្នកហូប អ្នកហូប៧ ៨ ៩!!

កៈ កូនបង្កើត កូនបង្កើត?

ខៈ កូនបង្កើត៦។

កៈតែ៦នាក់ទេហេ?

ខៈ ៦ស្រី៣ប្រុស៣។

កៈចាំ!!

ខៈដល់គិតមកជុំគ្នានេះ ៨។

កៈ នេះឈ្មោះកូនទាំងអស់ហ្នឹងមីងហី?

ខៈហ្នឹងហើយ។

កៈ វិបុល បូរីហ្នឹងអ្នកណាគេ?

ខៈហ្នឹងត្រឹមហ្នឹងហើយអាពៅហ្នឹង!!

(កូន)៖ អាពៅ។

កៈកូនរបស់មីងដែរតើហី?

ខៈ បានមួយអាទិត្យហើយហ្នឹងហិ!!

កៈចាំ!!អ៊ីចឹងឥឡូវ មីងប្រាប់ឈ្មោះកូនសិន កូនទាំង៦នាក់ហ្នឹងឈ្មោះអីគេខ្លះ?

ខៈ វិបុល ស្រីមុំ។

កៈមួយទៀត?

ខៈ វិបុល និមល វិបុល បូរី វិបុល ភាស្ស វិបុល បូរ៉ា វិបុល បុរី។

កៈ
ឥឡូវញ៉ុមមើលនៅក្នុងសៀវភៅស្នាក់នៅរបស់មីងម៉ងទៅឈ្មោះពូគាត់អ្នកមីងនិយាយមកមិញត្រូវទាំងអស់មិញអ៊ីចឹងទាំងថ្ងៃខែឆ្នាំកំនើតរបស់ប្តីមីងនឹងកូនរបស់មីង!!
អ៊ីចឹងញ៉ុមអានអីខេអ៊ីចឹងប្តីរបស់មីងគាត់ឈ្មោះអោម វិបុល លោកពូកើតនៅក្នុងថ្ងៃទី៦ខែ០១ឆ្នាំ១៩៦១ នៅភូមិសារិកាកែវ ឃុំសារិកាកែវ ស្រុកល្វាឯមខេត្តកណ្តាល ដល់ពេលកូនអ្នកមីងស្រីមុំ វិបុល ស្រីមុំហ្នឹងកើតនៅក្នុងថ្ងៃ០៣ ខែ០១ ឆ្នាំ១៩៨៥ នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កូនឈ្មោះវិបុល និមលកើតនៅក្នុងថ្ងៃ០៧ ខែ០៧ ឆ្នាំ១៩៩០ នៅភូមិលេខ១ ស្វាយរលំ ស្រុកស្អាងខេត្តកណ្តាលដែរ វិបុល បុរីកើតនៅក្នុងថ្ងៃ០៩ខែ០៥ឆ្នាំ១៩៩៣នៅភូមិជុំសារិកាកែវ ឃុំសារិកាកែវ ស្រុកស្អាង ខេត្តកណ្តាល វិបុល សម្ភស្សកើតនៅក្នុងថ្ងៃទី១០ ខែ១១ ឆ្នាំ១៩៩៦ នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល វិបុល បូរ៉ាកើតនៅក្នុងថ្ងៃ០៤ ខែ០៩ ឆ្នាំ១៩៩៩ នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាលដែរ វិបុល បុរីកើតនៅក្នុងថ្ងៃ០១ ខែ១១ ឆ្នាំ២០០២នៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាលដែរ!!ស្រីប៉ុន្មានប្រុសប៉ុន្មានមីងភ្លេចបាត់ហើយ។

ក៖ប្រុស៣ស្រី៣។

ក៖ ប្រុស៣ស្រី៣!!ចាំ!!ហ៊ីបាន
ហ៊ីអ៊ីចឹងបានពូជពង្សអ្នកមីងបានស្គាល់ទាំងអស់នេះហ៎!!ឡើងមួយខ្សែ
អ្នកណាចង់ដឹងអីវ៉ាន់ស្គាល់ឡើងមនុស្សកើតជំនាន់ណាជំនាន់ណាកើតទាំងអស់ហ្នឹងណាស់មីង!!

ខ៖ចាំ!!

ក៖ អ្នកមីងកូនអ្នកមីងទាំង៦នាក់អ្នកមីងមានអោយគាត់ទៅរៀនទាំងអស់គ្នាអីអត់?

ខ៖ បានរៀនស្រីមុំបានរៀនបានប៉ុន្មានថ្នាក់ទីប៉ុន្មានទី៥ទី៦ហ្នឹង។

ក៖ ចាំតែពួកគាត់សុទ្ធតែបានចូលសាលារៀន?

ខ៖ បានចូលសាលា។

ក៖ តែគ្រាន់តែបានតិចតួចអ៊ិចឹងទៅហោ?

ខ៖ បានតិចតួច។ក៖ចាំ!!ខ៖ បើនិមលបានចូល៧ឆ្នាំអត់ចេះអីតែបន្តិច។

ក៖ ហើយក៏ឈប់រៀនទៅ?

ខ៖ វាថាឈប់រៀនទៅ!!ទៅរៀនទៅអីអញហាត់ចង់ងាប់ហើយ។

ក៖ រៀនអត់ចេះទៀតហោ?

ខ៖រៀនអត់ចេះតែស្រះ អ ស្រះ
អត់ចេះផងហ្នឹងទៅយំតែប្អូនៗយកទៅលុយទៅរៀនចេញមកប្រហែលហ៊ីហែវបាយណាស់
ហ៊ីឈឺពោះណាស់ ជួនកាលប្អូនអត់លុយដើរខ្ចីគេអោយអាប្អូនអាប៊ូរីហ្នុំ!!

ក៖ ចាំហ្នឹងហើយ អ៊ីចឹងអ្នកមីងនិយាយពីជីវិតមីងនៅក្នុងជំនាន់ប៉ុល ពត!! ឥឡូវលន់
នល់មុនសិន!តែពេលលន់ នល់ចូល!!

ខ៖ ញុំមនៅតូចពេក!

កៈ នៅលន់ នល់ ឥឡូវអ្នកមីងចាំអីគេខ្លះពេលទំលាក់គ្រាប់បែកហ្នឹងម៉េចដែរជីវិតរបស់មីង?

ខៈ ហុីញុំមនៅលន់ នល់ហ្នឹងកាលអើយនៅតូចដូចឃើញតែគេទំលាក់គ្រាប់បែក
វ៉ែគ្នាជំលៀសញុំមទៅសំប៉ាន។

កៈចាំ!!អាហ្នឹងពេលទំលាក់គ្រាប់បែកហ្នឹងមីងរត់ទៅសំប៉ាន?

ខៈ ហ្នឹងហើយ។

កៈ នៅកោះធំណោះហោ?

ខៈ ហ្នឹងហើយ។

កៈ មានដែលឃើញគ្រាប់បែកអីវ៉ាន់មានដែលងើយមើលលើឃើញអីវ៉ាន់អត់មីង?

ខៈ ហុីអាជំលៀសទៅអីវ៉ាន់ហ្នឹង ណោះដេកនៅម៉្លុំក្រោយនេះហ្ន៎ដើមចារនេះហ្ន៎
ដេកដេកអុីចឹងទៅអាគេបាញ់គ្នា
អាគេបាញ់ឆត្រ័ភ្លើងឆត្រ័មកភ្លឺអោយពេញហើយឃើញពួកទព័ហ្នឹងគេការពារនៅគៀនៗអោយ
យើងចុះទៅទាំងវ៉ូង
គេនៅអញ្ចឹងទៅហើយដល់ហើយយើងដើរអុីចឹងទៅយើងចាស់ៗដល់តែដើរដល់ទៅកន្លែងព្រៃ
កថី ព្រៃកតូចនេះ អាបេត្រូវចាក់ញុំមណោះញុំមលីកន្ទេលតូច ហើយលីកន្ទេលមិនដឹងប៉ុន្មានទេ
ដល់អន្លង់គេប៉ុននេះគេជីកអោយយើងជ្រៅណាស់ ចាស់ៗស្រែកនាំគ្នាទៅរកកន្លែងចូល
ញុំមណោះផ្លោះចូលផ្លុកយកអាកន្ទេលក្របដល់ហើយផ្អែរំលងទៀតបើអាកន្ទេលហ្នឹងឃើញអា
កាប៉ាល់ហោះហ្នឹងហោះ លែងកំពុងតែសើចមានស្អីឮស្លូវតែដុង
មានអីដាច់ស្ពានចាស់ៗនាំគ្នាយំ ញុំមណោះមិនដឹងម៉ែញុំមនៅឯណាទេ
ដើររកម៉ែគិតតែប្រចោរម៉ែចុះរត់ចោលកូន អត់ដឹងខ្យល់អី!!ម៉ែថាមីអូនម៉ែនៅណោះ
(គាត់ជេរម្តាយគាត់ពាក្យមិនល្អ) អញនៅតែម្នាក់ឯងចុះបើកន្ទេលក្របចុះបើអត់ដឹង
បើងាប់ងាប់ទៅ បើងាប់អត់ដឹងថាងាប់រឿងអីផងទេ។

កៈហ្ន៎!!

ខៈ វរវរគឺស្លូរអត់ដឹងថាងាប់រឿងអីផង។

កៈ ចេះដេរម៉ែតាំងពីតូចមក?

ខៈ ហ្ង!!ម៉ែប្រចោរទុកចិត្តចុះ ពេលជំលៀសទៅដល់កណ្តាលផ្លូវឃ្លានបាយ ម៉ែញ៉ុមឃ្លានបាយ
មានអាតានោះគាត់នំបញ្ចុកគាត់ស៊ីតែមួយគ្រួសារគាត់ អោយគាត់ដាក់មួយចានអត់
ខឹងពេកទាញអាចាននំបញ្ចុកគប់ក្បាលគាត់ ថាតាឯងច្រាស់តែឯង។

កៈ មីងឆ្នាស់ម៉ង!!

ខៈ ដល់ហើយគាត់នាំគ្នាលួងដល់ហើយទៅដល់ជិះដល់
ស្អីព្រៃកអំបិលពួកទាហានគេចេញមកយកយើងបណ្តោះគ្នាទៅសួរប្រវត្តិម៉ែធ្វើអីឪធ្វើអីអ៊ីចឹង
ទៅណាស់ ដល់ហើយអើរឪញ៉ុមពេលមុនគាត់ធ្វើទាហានដែរ
ដល់ហើយគាត់បានម៉ែញ៉ុមគាត់ឈប់ធ្វើទាហានទៅ
អាហ្នឹងព្ទគេនិយាយទេណាស់ញ៉ុមថាអត់ដឹងផងហ្នឹង
ញ៉ុមអត់ដឹងចេះតែលឺម៉ែខ្សឹបថាហ៊ីបើគេសួរថាម៉ែឪធ្វើអីថាអត់ដឹងទៅ កុំអោយគេយកឪទៅ ។

កៈចាំ!!ចេះតែឆ្លើយតាមគាត់ទៅ។

កៈ ចាំ !!ហើយឥលូវមីងចូលមកប៉ុល ពតវិញម្តងអាថ្ងៃចូលមកប៉ុល ពតមីងម៉េចដែរ?

ខៈ ហ៊ី!!

កៈ អាហ្នឹងដឹង អាហ្នឹងចាប់ផ្តើមដឹងច្រើនម៉ង!!

ខៈ អាហ្នឹងដឹង លឺចាស់ៗថាអញ្ចេក នាំគ្នារត់ទៅរកម៉ែឪទៅប្រធានគេហ្នឹង
ថាអញ្ចេកពួកក្មេងៗអើយ!!ទៅរកម៉ែឪញ៉ុមណោះទៅរកម៉ែនៅមន្ទីរពេទ្យ ដល់ទៅជួបម៉ែ
ម៉ែថាតោះកូន ហើយប្អូនញ៉ុមឈឺទៀត កើតចេញកញ្ជ្រិលនោះ បិទភ្នែកទៅ
អាដីហុយនោះនេះអត់កើតទេ អាហ្នឹងដូចគេថាចង់ទៅហើយឬក៏មិនដឹង
ដល់ហើយម៉ែថាទុកចោលនៅនឹងគល់ពោធិ៍ហ្នឹងហើយ
អ៊ំអីវ៉ាន់គាត់ថាអញ្ចេកទុកចោលហ្នឹងទៅយកទៅធ្វើអី
យកអីវ៉ាន់ទៅយកខោអាវយកសំលៀកបំពាក់ទៅ
កុំយកវាទុកអោយវាសុខសប្បាយនៅហ្នឹងទៅ អោយវានៅហ្នឹងទៅ។

កៈ ប្អូនមីងរាល់ថ្ងៃហ្នឹង?

ខ៖ ហ្នឹងហើយ អោយដាក់នៅនឹងគល់ដើមពោធិ៍ក្រោមនេះ ដល់ហើយញ៉ុមថាអញ្ចេកម៉ែ ងាប់ហើយចាំទៅងាប់ជាមួយយើងទៅម៉ែ ម៉ែនោះអត់យកអីទេបីតែប្អូន ញ៉ុមស្ពាយខោអាវប៉ុន្មានប្រហែលជា២កំប្លេមិនដឹងស្ពាយរត់ទៅតាមគាត់ទៅដល់តាខ្មៅនេះអាកន្លែងដើមស្រល់នេះផ្ទះអាខាងណោះហ្នឹង ញ៉ុមយកបានតើ!!គេដេញ គេដេញចេញតើ!!!

ក៖ហ្ហូស្គាល់!!

ខ៖ ដូចនេះដូចផ្លូវយើងអញ្ចឹងនេះអាកន្លែងដើមហ្នឹង។

ក៖ ហ្នឹងហើយហ្នឹងហើយស្គាល់នៅជិតអាកន្លែងកាច់ជ្រុងអ្នកតាចិននេះហ្នឹងហី?

ខ៖ អាកន្លែងសួនច្បារតាខ្មៅ!!

ក៖ហ្ហូៗ!!

ខ៖ អាកន្លែងដើមស្រល់ហ្នឹង ។

ក៖ចាំ!!

ខ៖
ហ្នឹងផ្ទះហ្នឹងញ៉ុមយកបានចូលមើលទៅខាងក្រោមហ្នឹងគេមានផ្ទះគេហ្នឹងប៉ុន្មានជាន់នៅខាងក្រោមទៀតហ្ហូ!!

ក៖ហ៊ុៗ!!

ខ៖
ញ៉ុមចូលទៅមើលហើយអ៊ំញ៉ុមគាត់នៅនេះអញ្ចឹងទៅគាត់អោយញ៉ុមទៅនៅខាងក្នុងហ្នឹងគេបើកភ្លើងបើកអីហ្នឹង!!!

ក៖ អ៊ីចឹងជំលៀសហ្នឹងមិនមែនជំលៀសទៅក្រោម ទៅទៅឡើទៅលើវិញ?

ខ៖ អើយ៧៩(១៩៧៩)ហ្នឹងគេអោយយើងឡើងមកលើវិញហ្នឹង!!

ក៖ហ្ហូ!!

ខ៖ មកណោះវិញ។

ក៖ ហ្នឹងនេះហី ពេលបែកចូលប៉ុល ពតមិនមែននេះទេណាស់ អាពេលថ្ងៃដំបូង
អត់ទាន់អាពេលថ្ងៃបែកនេះទេ ឆ្នាំ៧៥(១៩៧៥)អាពេលចូល។

ខ៖ ហ្នំ៧៥(១៩៧៥)ទៅមកសំប៉ានហ្នឹងតែម្តងហ្នឹងទ័ពគេមកដល់ត្រឹមហ្នឹងគេជំលៀសទៅម៉ង!!

ក៖ អ៊ីចឹងមិញនិយាយហ្នឹងអាហ្នឹង៧៩(១៩៧៩)ហ្នឹងបែកមកហើយហ្នឹង?

ខ៖ ហ្នឹងហើយ។

ក៖ ញ៉ុមសួរសំនួរខុសពេលបែក!!

ខ៖ អាហ្នឹងសួរពេលជំនាន់!!

ក៖អាពេលចូល!!

ខ៖ មិញសួរជំនាន់ប៉ុល ពត។

ក៖ ចាំឥឡូវនិយាយពីថ្ងៃដំបូងនៃការចូលជំនាន់ប៉ុល
ពត១៩៧៥ម៉េចដែរមីងថ្ងៃដំបូងហាំមីងហាំ??មីងមានដឹងថាម៉េចបានមានប៉ុល ពតហ្នឹង?

ខ៖ មុនដំបូងញ៉ុមលឺតែចាស់ៗថាអញ្ចេក កុំអោយទៅលេងណាឆ្ងាយៗប្រយត្ន័ពួកអាធ្មេញខ្មៅ
មិនដឹងពួកអាធ្មេញខ្មៅម៉េចទេ!!ពួកអាធ្មេញខ្មៅចាប់ករចេះតែថាអញ្ចឹងទៅណាស់
ហើយដល់ពេលយប់ឡើងថាញ៉ុមគាត់មានគោ
គាត់ប្រចោរគ្នាពេញភូមិគាត់ហៅប្រពន្ធគាត់មកជួយដឹកគោហើយអាទ័ពគេគិតតែថាតាអោយ
លឿនឡើងតា តាអោយលឿនឡើងអាង!គេវ៉ៃគ្នានោះ គេរកវ៉ៃគ្នាណាស់
ដល់ហើយទព័ហើយទព័វាជួបគ្នាហើយញ៉ុមនៅនឹងព្រៃកនេះហ្នឹងគេផ្លោងពីនេះទៅហើយទា
ហាន ទព័លន់ នល់ នៅខាងណោះទព័អើយ ទព័ពួកប៉ុល
ពតហ្នឹងគេនៅខាងណោះផ្លោងព្រៃកម្ខាងម្នាក់ហ្នឹង ហើយញ៉ុមនៅជិតព្រៃកហ្នឹង
ទៅពួននៅតែក្រោមដើម ដើមត្នោតហ្នឹង ឃើញតែភ្លើងពៃរអ៊ិចឹងលឹបផ្លឹប
ពៃរលឹបផ្លឹបទំរាំតែនឹងចេញទៅដល់ក្រោយហ្នឹងអើយវេទនាណាស់
ប៉ុនៗនឹកឃើញសប្បាយអត់ដែលសួរឃើញគ្រាប់ធ្លាប់តែឃើញភ្លើងដូចអំពិលអំពែក។

កៈ អាហ្នឹងតែចំងាប់ហាំមីងហាំ!!សប្បាយអីគេ!!

ខៈ បើមិនអ៊ីចឹងអាបេទំលាក់មកនៅសើចតែកកឹកទេ
ឃើញតែគេស្លាឆ្អន់មានអាខ្លះយំអាខ្លះស្រែកបានហ៊ីធ្វើភ័យដែរហ្នឹង
អត់ទាំងដឹងខ្យល់ផងហ្នឹង។

កៈ ទៅអ៊ីចឹងវិញមីង!!ដល់ទៅឃើញគ្រាប់អីវិញទៅសប្បាយវិញ!!

ខៈ ហេឃើញភ្លើងហើយឃើញអាគេបាញ់ឆត្រ័គេបំភ្លឺផ្លូវអោយយើងដើរទៅហ្នឹងស្មានតែ!!

កៈ បាញ់ឆត្រ័ហ្នឹងដើម្បីបំភ្លឺផ្លូវ?

ខៈ អោយប្រជាជនចុះទៅ ។

កៈហ្អំ!!

ខៈពួកប៉ុល ពតហ្នឹងទ័ពហ្នឹង ប៉ុល ពតហ្នឹង។

កៈ អ៊ីចឹងពេលហ្នឹងលន់ នល់ ខ្មេចខ្មីអីអស់ហើយមីងណោះ?

ខៈ លន់ នល់វានៅខាងណោះវានៅខាងមាត់ព្រែកហ្នឹង។

កៈចាំ!!

ខៈ នៅមួយចំហៀងម្នាក់!!

កៈ អាហ្នឹងពេលនៅដំបូងពេលជិតចូលប៉ុល ពត?

ខៈហ្នឹងហើយ!!

កៈជិតចូលទៅចូលទៅហ្នឹងហោ?

ខៈ ចាំញ៉ុមចុះទៅទៅ។

កៈ ចុះដល់ពេលចូលដល់ប៉ុល
ពតមែនទែនដែលគេជំលៀសមីងទៅសំប៉ានហ្នឹងតើមីងជួបរឿងអីគេខ្លះពេលជំនាន់ហ្នឹង?

ខ៖ ទៅដល់ណោះ!!

ក៖ បានដឹងថាពិបាកម៉េច!!

ខ៖ ទៅដល់ណោះគេអោយនៅផ្ទះមូលដ្ឋានគេហ្នឹង។

ក៖ចាំ!!

ខ៖ គេអោយយើងនៅអីចឹងទៅគេមិនមែនអោយយើងហូបទេណាស់
យើងទៅរកទៅរើសត្រូវករគួរទៅកន្លែងថ្នូរទៅកន្លែងចំការអីចឹងទៅពីរនាក់ម៉ែកូនហ្នឹងទៅរើស
បានមួយកញ្ជើរមួយកញ្ជើរអីចឹងទៅ
ទំរាំតែទូលមកដល់កន្លែងផ្ទះនេះវិញសន្សំបានច្រើនអីចឹងទៅបានដឹកអង្ករមកនៅសំប៉ាន
ណោះដល់ពេលបែកចុងឆ្នាំ៧៤(១៩៧៤)ចុងឆ្នាំហ្នឹងដល់ហើយកិនអង្ករហ្នឹងយកមកយកណោះ
៧៥(១៩៧៥)។

ក៖ចាំ!

ខ៖មកដល់មិនដឹងដើមឈើមិនផ្ទះមិនដឹងសម្បែងនៅណានឹកឃើញពីណោះមកហ៊ីទៅដល់
ទៅនៅផ្ទះយើងវិញម៉ែបានស្រួល មានស្អីផ្ទះឃើញតែកំទេចហ្នឹង ឃើញតែផេះ
ឃើញតែធ្យូង។

ក៖ គ្រប់ផ្ទះអញ្ចឹងសុទ្ធតែឆេះអញ្ចឹងទាំងអស់??

ខ៖ អស់រលីង  វាលល្វឹងល្វើយតាំងពីសិត្បូមកអត់ឃើញដើមឈើឃើញឡាន
ឡានកញ្ចស់ៗ!!គេដុតចោលហ្នឹង។

ក៖ ពួកអាឆ្កួតអស់ហ្នឹង។

ខ៖ បំផ្លិចបំផ្លាញ មិនដឹងអាណាមិនដឹងអាខ្មៅមិនដឹងអាសរ។

ក៖ តែញ៉ុមដឹងថាពេលហ្នឹងលន់ នល់គឺរលាយអស់រលីងហើយ!!

ខ៖ ហ្នឹងហើយ។

ក៖ ពេញចូលមកអាពតពេញលេញហ្នំ!!

ខ៖ ពេញលេញមកអស់ហើយហ្នឹងមិនដឹងទៅខាងណាផងហ្នឹង រំសាយ ខ្លះរត់ទៅប្រពន្ធកូនជំនាន់ហ្នឹងវិញគេគាបសង្កត់វិញហើយគេសួររកហើយអ្នកណាធ្វើទាហានខ្លះហើយ។

ក៖ហ្នឹងហើយ!!

ខ៖ ដល់មានជាប់ខ្សែស្រលាយអីទៅ គេយកឃុំយកអីអស់ទៅហើយ។

ក៖ យកឃុំម៉េចមីង?

ខ៖ យកទៅវ៉ៃចោលហ្នឹង ភូតយើងទៅយកឃុំ។

ក៖ នៅក្នុងព្រៃអញ្ចឹងទៅហោ?

ខ៖ ទៅជួនណាលទៅជីកគល់ជីកអីអឺចឹងអឺចឹងទៅ!!

ក៖ បោកច្រើនណាស់អឺចឹងពួកប៉ុល
ពតមីងហោ??មីងពេលហ្នឹងមីងឃើញមានទាហានច្រើនហោ?

ខ៖ ញ៉ុម ញ៉ុមនៅជិតហ្នឹង ជិតនេះអញ្ចឹង មានអើយពួកអាពត!!ពួកអាពត!!

ក៖ ភាគច្រើនពួកអាហ្នឹងសុទ្ធតែអាវខ្មៅ!!

ខ៖ ខោអាវខ្មៅហ្នឹង
គេមកគេអភិវឌ្ឍន៍ជាមួយចិន!!ដល់ចិនហ្នឹងគេដឹកសំភារៈមកធ្វើលើព្រែកហ្នឹងគេធ្វើ
!!កន្លែងហ្នឹងដូចដឹងរោងចក្រអីគេទេសុទ្ធតែដេកហើយគេយកស្អីយកដែកអីយកមកដាក់អីហ្នឹងគ្នាគេហ្នឹង
ជាមួយអាចិនហើយខ្មែរយើងហ្នឹងហើយនារីនារីអីហ្នឹងក៏ប៉ុន្តែគេស្រែក!គេធ្វើស្រូវធ្វើអីដែរហ្នឹងដែរតើពួកគេហ្នឹងកន្លែងក្រោយវត្តព្រែកសំរោងយើងហ្នឹង
គេធ្វើស្រូវធ្វើអីញ៉ុមទៅហើយទៅសន្ទុំស្រូវនៅហ្នឹង
ទៅសន្ទុំអឺចឹងទៅជាមួយអ្នកឃ្វាលគោសុំគេទៅជាមួយហាំ!!យកប្អូនទឹមតែបានមួយខែពីរខែទៅហើយ។

ក៖ចាំ!!

ខ៖
ទៅរើសស្រូវហ្នឹងទៅវិចបង្វិចមកដល់ហ្នឹងទំរាំមកដល់ផ្ទះធូន់យ៉ាងណាមិនដឹងប៉ុន្មានទេតែធ្ងន់តែរហូតហ្នឹង។កះចាំ!ខះហើយមាឧល្អិតផងហ្វូយំតាមផ្លូវមកដល់ចិញ្ចឹមម្ដាយអោយម៉ែអញ្ចឹងទៅម៉ែបានអាស្អីមួកដែកនោះ។

កះ មួកទាហានហ្នឹងហី?

ខះ ហ្នឹងហើយ។

កះ កំមាលគេហៅកំមាលហ្នឹងហី?

ខះ មិនមែនកំមាលទេ មួកដែកយកមកបុកស្រូវ។កះចាំ!!ខះ ខ្លួកៗៗ។

កះ នៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

កះ ហើយពេលបុកស្រូវបុកអីហ្នឹងពួកប៉ុល ពតហ្នឹងវាអត់មកអត់អីទេហី?

ខះ អត់អីទេ ពីព្រោះអីអញ្ចេះវាមិនទាន់ចូលពេញសិទ្ធនៅឡើយនៅវាយប៉ាយនៅឡើយទេណាស់រកកន្លែងក្រុមអីមិនទាន់សូវឃើញទេ!!

កះចាំ!!

ខះគេមិនទាន់បែងចែកធ្វើផ្ទះអោយទេ
ដល់ហើយបុកស្រូវអញ្ចឹងទៅម៉ែមើលប្អូនមើលអីអញ្ចឹងទៅព្រឹកឡើងដាំបាយអោយហូបទៅទៅខាងក្រោយវត្តហ្នឹងហើយឆ្ងាយទៀតហាំ!!!
ហើយមើលឥឡូវហ្នឹងមួយភ្លែតហ្នឹងលើកមុនដើរកាត់ព្រៃកាត់ផ្សេងយំផងអីផងទំរាំទៅដល់ពួកនារីហ្នឹងវិចជូនណាលគេអានិតមិនដឹង
ដាក់ក្រមាហ្នឹងអោយមកមិនបាច់ទៅរើសទេអូននៅអង្គុយនៅហ្នឹងទៅ។

កះចាំ!!

ខះ
នៅអង្គុយហ្នឹងទៅដល់ម៉ោងគេដេញគោមកមកតាមគេមកហើយមានអញ្ចឹងហើយមីងកូនខ្ចី

ទៀត មីងកូនខ្ទីឈ្លោះជាមួយប្តីគាត់បីកូនទៅហ្នឹង ម៉ែបុកស្រូវហ្អែង
ទំរាំតែបានបបរអោយហូបហ្នឹង។

កៈ ឈ្លោះគ្នាទៀតអាកំពុងសង្គ្រាមហើយសោះ?

ខៈ មីងញ៉ុមស្លាប់ដោយសារឈ្លោះគ្នាតើ!!

កៈ ម៉េចអញ្ចឹងវិញ?

ខៈ គាត់ផ្លឹកម្តង ចាំមើលគាត់ធំហ្នឹង ដំបូងគាត់ចាប់អាពស់ថ្លាន់
ដល់ចាប់ពស់ថ្លាន់ដូចថាប៉ះចំស្អីគេអាម៉េចទេ!!ប៉ះចំអាស្អីក្រឡាម៉េចនោះ ក្រឡាសយ
ដល់ហើយក៏ហើមជើង ដល់ហើមជើងពោះធំមួយហ្នឹងឆ្លងទន្លេទៅហើយណាស់
ដល់តែពេលហើមជើងភ្លឹក
គាត់ថាទៅសប្បាយណាស់ទៅដល់គេសុទ្ធតែមានហើយគេរត់យំតាមគេទៅដល់គេទារជូនមក
ផ្ទះគាត់ទៅដេកនៅក្រោមពោធិ៍
ដល់ដេកនៅក្រោមដើមពោធិ៍នៅហ្នឹងគេមកតាមលបមើលឃើញគាត់គេទៅយកមករុញ
គេទៅយកមកឃើញព្រោះគាត់ហើមហើយណោះ
ជើងឡើងហៀរទឹកដល់ហើយច្រានគាត់ទៅផ្កាប់
មុខគាត់ថាផ្កាប់មុខហើយទៅរាងដឹងខ្លួនតិចៗទាររកទឹកនាំគ្នាបន្តក់ទឹកទៅហ៊ីមានអីដល់គាត់
ពោះធំទៀតឆ្លងទន្លេអត់រួច។

កៈ ស្លាប់ទៅ?

ខៈ ស្លាប់ទៅគេដឹកយកទៅកន្លែងមន្ទីរពេទ្យមានណាមីងស្លាប់តាំងពីនេះទៅ
នៅសល់កូន២ស្រីទាំង២។

កៈ អញ្ចឹងអ្នកមីងចូលសម័យប៉ុល
ពតសប់ម៉ងហាំ!!ពេលចាប់ផ្តើមកាប់សម្លាប់មួយៗភ័យអត់ទេមីងពេលមានឮសម្លាប់គ្នាមុនដំបូ
ងយើងដឹងហើយថាចូលសង្គ្រាមយើងមួយៗអត់មានគិតថានឹងស្លាប់អីច្រើនអីណាស់ណាហើ
យសម្លាប់ចំលែកទេអ៊ីចឹងមីងណោះ!!

ខៈ ចាំមើលគ្រាន់លឺថាណែគេយកវ៉ៃចោល
ធ្វើអោយត្រឹមត្រូវម៉ែញ៉ុមមិនដឹងអាម៉េចអីអាម៉េចទេ!!ម៉ែញ៉ុមនឹកឃើញខ្លាចតែម៉ែញ៉ុមគេយក

ទៅវ៉ៃចោលទេ!!យកឪពុកវ៉ៃចោលហើយម៉ែទៀតតែអត់ពីម៉ែមិនដឹងម៉េចទេញ៉ុមមានតែ២នាក់បងប្អូនហ្នឹងប៉ុន្តែគេចេះតែអានិតដែរមានអាប្រធានភូមិឃុំនោះគេអានិតថាអើរកុំយកទៅអត់មានអ្នកណាមើលកូនមើលចៅហើយម៉ែញ៉ុមប្អូនញ៉ុមប៉ុនឈឺណាស់ ដូចអត់អោយម៉ែធ្វើការម៉ងមួយថ្ងៃហីក៏២ថ្ងៃមកមើលកូនគេអញ្ចឹងទៅគាត់ទៅនេះទៅពេទ្យហាំ!!ហើយមីនេះឈឺរហូតដល់បែកអាពតហ្នឹងឃើញបីមកពីមន្ទីរពេទ្យហ្នឹងឃើញជិតងាប់គេអោយក្រវៀតចោលនឹងគល់ពោធិ៍ហ្នឹង។

កៈ អើរតែហេងវិញចេះរស់ដែរមីងណោះប្អូន?

ខៈ ដល់ហើយបានពេទ្យវៀតណាមទេ។

កៈហ្ហ៎!

ខៈ ពេទ្យវៀតណាមគេបន្តក់ថ្នាំស្អីគេទេដល់ហើយធ្វើម្ហូបៗ វាអត់ដាច់ដង្ហើម
បើដាច់ដង្ហើមក៏យកទៅក្រវៀតចោលហើយតែវានៅផ្លឹកៗៗប៉ុន្តែម៉ែញ៉ុមប៉ុនមើលជំងឺណាស់អត់បាយរាប់ខែហាំគាត់ដាក់តែបានតែនឹងក្រមាបបរណាស់ដាក់នៅលើតែទ្រូងហ្នឹងហើយម្ហូបៗហើយអាថ្ងៃហ្នឹងរកផុតតែដង្ហើមទេ
ប៉ុន្តែព្រលឹងព្រលះអត់មានទេ!!ភ្នែកដីហុយពេញក្នុងភ្នែកហ្នឹងភ្នែកបើកដីហុយមកញ៉ុមគិតមិនល្អទេ ភ្នែកវាម៉ែឯងមិនគិតជូតចេញម៉ែ
ម៉ែគិតតែឃំបីបណ្តើរឃំបណ្តើរអាគេអោយបោះចោលញ៉ុមថាម៉ែកុំបោះចោលទុកទៅ!!

កៈ ចេះតែរស់ដែរហោ?

ខៈ ទៅងាប់ណាចេះតែទៅទៅ!!

កៈ ម៉េចបានគាត់ផុតវិញ?

ខៈ ពេទ្យវៀតណាមចាក់ថ្នាំ!!

កៈ ហ្ហ៎ហ្នឹងហើយ។

កៈ វៀតណាមចាក់ថ្នាំអោយ។

កៈ មីងប្រាប់មិញដែរ។ មីង មីងធ្វើការអីគេខ្លះនៅក្នុងជំនាន់ប៉ុល ពត?គេបញ្ជារធ្វើអីគេខ្លះ?

ខ៖ ញុំមទូលអាចមន៍គោកាប់ផាងខេត្រ ទូលអាអាចមន៍មនុស្សហ្នឹង!! អាផែនប៉ុននេះហ្នឹង!!

ក៖ ទូលអាហ្នឹងដែរ?

ខ៖ ហុីគេធ្វើផែនប៉ុនៗនេះ ដល់ធ្វើហើយគេចាក់អញ្ចឹងទៅ!!វាស្ងួត!!

ក៖ លែងស្អុយលែងអីអស់ហើយហេ?

ខ៖ ហុីស្អុយហ្នឹង ប៉ុន្តែនៅក្មេងមិនចេះដឹងអី
បើកាឡុកកាឆាដូចចាប់ឆាយដែរហ្នឹងចេះតែទៅតាមគេតាមឯងបើគេទូលកើតយើងទូលកើត
ដែរហើយ ដល់ហើយទូលមួយដុំហ្នឹងទៅ!!ហុីក្បាលអាគូទកញ្ជើហ្នឹងឡើងទំពែកអស់ហើយ
ក្បាលហ្នឹងអត់មានសក់ទេ
ចុះទូលម្តងវាមិនដាច់បន្តិចទំរាំតែដើរដល់ហើយក្តៅក្បាលផងណាក្បាលទទេហ្នឹងអត់មានអី
ទេចេះតែទៅតាមគេតាមឯងអីចឹងទៅខ្លះណាដើរកាប់ផាងខេត្រនៅក្នុងព្រៃកហ្នឹង។

ក៖ មីងពេលនៅប៉ុល ពតមីងនៅណាវិញនៅសំប៉ាននោះ?ឬក៏នៅនេះ?

ខ៖អី ជំលៀសទៅសំប៉ានអាហ្នឹងអត់បានដល់១ឆ្នាំផងហ្នឹងគេហៅជំលៀសចាស់
ដល់យើងឡើងមកវិញ៧៥(១៩៧៥)ជំលៀសចាស់បានគេអត់បញ្ជូនទៅនេះហ្នឹង
ទៅបាត់ដំបងបាត់អីអីចឹងហាំ!!

ក៖ អីចឹងនៅផ្ទះនៅអីហ្នឹងវិញទៅ?

ខ៖ ហ្នឹងហើយ យើងជំលៀសចាស់។

ក៖ ចាំ!!ហេងហើយអីចឹងហេ?

ខ៖ហ្នឹងហើយហេងហើយ។

ក៖ មីងដែលឃើញមនុស្សគេសម្លាប់ចោលអីវ៉ាន់អីអត់?

ខ៖ អត់ដែលទេ ទាល់តែបែក៧៩(១៩៧៩)ឃើញម្នាក់គត់

ក៖ ម៉េចវិញទៅមីងបានស្លាប់?

ខ៖ ប្រធាន ប្រធានកោះគរ។

ក៖ អូ!!កោះគរហ្នឹងឮល្បីណាស់!!

ខ៖ គេយកមក គេចាប់បានថាពាក់អាវពជាន់
ដំបូងពណ៌ក្រហមដល់គេស្គាល់មុខចេះតែរត់ៗទៅមុខទៀត
ដោះអាវក្រហមចេញពាក់ពណ៌ពងក្រសាដោះអាវហ្នឹងទៀតចេញពណ៌សរដល់គេចាប់បានវៀតណាមគេយកមកកាត់ទោសគេយកមកបាញ់ចោលកន្លែងនេះ។

ក៖ អាពតដែរអាហ្នឹងហោ?

ខ៖ អាហ្នឹងអាអ្នកនេះហ្នឹងហាំមិនមែនអាពតទេ៧៩(១៩៧៩) យើងនេះ!!

ក៖ អាអ្នកអីគេវិញ?

ខ៖ អាហ្នឹងប្រធានកោះគរហាំ!!ម្នាក់ៗហ្អែងសម្លាប់ប្ដីអញ!!

ក៖ហ្នឹងហើយពួកអាសម្លាប់មនុស្ស!!

ខ៖ ហ្នឹងហើយ!!ដល់ហើយលោកអើយគេបាញ់ គេរកបាញ់ទៅគេរុញទៅ
ហើយវាអត់មានញញើតអីបន្តិចទេ។

ក៖ វាខ្លាំងម៉ង!!

ខ៖ ហ្នឹងហើយ
!!ណែរៀបយកបាញ់ចោលគេនៅអាលែងប្រជុំគ្នាច្រើនហាំ!!វាគ្មានញាក់សាច់វាគ្មានញញើតអីបន្តិចទេ។

ក៖ ចឹអញ្ចឹងបានវាលើកដៃសម្លាប់មនុស្សទៅរួចហ្នឹងហាំ!!

ខ៖ ថាវាឆ្អែតឆ្អល់ហើយហ្នឹង ហើយដល់ហើយគេបណ្ដើរមកក៏ដោយអត់មានញញើតទេ
មកដល់កន្លែងគេបាញ់ចោលហ្នឹង គេច្រានទៅហើយនៅស្ទុះមករកគេទៀតហាំ!!

ក៖ រកវ៉ៃគេវិញទៀត?

ខ៖ ហ្នឹងហើយ ដល់ហើយគេដាក់មួយខ្នងពូថៅ ខ្នងនៅប្រវែប្រវ៉ាទាញគេ អាអ្នកកាន់កាំភ្លើងទាញមកដាក់ផ្លាយខួរហ្នឹងហា!!ក៏ផ្លុះហូរទៅ!!

ក៖ ហើយមីងឃើញម៉ងហោ?

ខ៖ ហ៊ីខានបាយឡើងចង់មួយអាទិត្យហ្ន៎!! តែក្បាលត្រីហូបខួរ តែខួរត្រី ខួរជ្រូក ខួរអីអត់ទេឥឡូវហ្នឹងនោះ!!អោយតែហៀបហូបហ៊ីនឹកឃើញខួរហូរនៅនឹងស្មៅហ្នឹងនឹកឃើញថាអញ្ចឹង!!

ក៖ អាហ្នឹងតាមពិតគេសម្លាប់សងសឹក!!

ខ៖ ហ្នឹងហើយ!!

ក៖ដោយសារវាហ្នឹងប្រធានកោះគរ!!

ខ៖ ប្រធានកោះគរ!!

ក៖ ហ៊ីសាហាវណាស់នៅហ្នឹងគេថាសម្លាប់មនុស្សនៅតែហ្នឹង។

ខ៖ អ្នកណាមួយអោយតែឃើញអាហ្នឹងមួយហ្នឹងហើយសម្លាប់ប្ដីអញ អានោះហ្នឹងហើយយកម៉ែអញទៅធ្វើបាប ម្នាក់ៗលឺតែឆ្លើយអញ្ចឹងទេមានតែពាក្យហ្នឹង!!

ក៖
អាហ្នឹងសាហាវម៉ងមីងណោះ!!ពាក្យថាប្រធានកោះគរមួយគឺថាអាហ្នឹងសាហាវខ្លាំងណាស់!!

ខ៖ ប្រធានវាប្រធាន គេចមិនផុតហើយអាហ្នឹង!!

ក៖ ចាំ!!អាសមអញ្ចឹងចុះដោយសារវាសម្លាប់គេច្រើនពេក ច្រើនមិនមែនតិចពាន់តិចម៉ឺននាក់ទេណាស់!!

ខ៖ ខ្លួនវាមួយហ្នឹង ក៏មិនញញើតមិនស្ដាយជីវិតវាដែរមីនាង គ្មាននឹកឃើញជីវិតវាសម្លាប់គេ សម្លាប់ឆ្អែតឆ្អល់ហើយហើយនោះ!!

ក៖ ញ៉ុមឆ្ងល់មិនដឹងអ្នកណាគេបណ្ដុះគំនិតវាដល់ថ្នាក់ហ្នឹងមីងណោះ?បានកើតអ៊ីចឹងណាស់!!

ខ៖ ប៉ុនបានថាខ្ញុំនិយាយទៅគ្មានទេ!!

ក៖ ចិត្តឯងតែម្តង!!

ខ៖ ចិត្តឯងហើយមិនមែនអ្នកថ្នាក់លើបញ្ជាមកទេ!!

ក៖ វាចង់ម៉ង!!

ខ៖ ប៉ុល ពតថាបញ្ជារមិនមែនទេបើញ៉ុមគិតទៅណាស់ តែគ្នាយើងហ្នឹង!!

ក៖ហ៊ឺៗ!!

ខ៖ ចង់បានតែធំគ្នាយើងហ្នឹង!!

ក៖ ហ្ហ៎ដោយសារដណ្តើមអំណាច!!

ខ៖
ដោយសារដណ្តើមអំណាច!អាគេណោះគេដាក់អោយតែបន្តិចអាឯងណោះថែមអោយពេញហ្នឹងហាំ!!

ក៖ហ្ហ៎!!

ខ៖ បើញ៉ុមចិត្តញ៉ុមគិតទៅ
មានគេយ៉ាងច្រើនតែមួយបន្តិចទេអាឯងនេះដាក់អោយពេញគ្នាឯងណោះ!!

ក៖ ហ៊ឺឆ្កួតសុទ្ធម៉ង!!

ខ៖ បើមិនអ៊ីចឹងយកអាក្មេងប៉ុនៗមេដៃហៅមិត្តម៉ែហៅមិត្តអឺ ជូនណាលសុទ្ធតែមិត្តម៉ែ
ជូនណាលហៅម៉ែហ្នឹងអីវ៉ាន់ចង់ទៅរ៉ៃចោលអីវ៉ាន់ណោះហ្នឹង!!ម៉ែឯងធ្វើអោយត្រឹមត្រូវណាស់
ប្រយត្ន័ញ៉ុមទៅប្តឹងគេណាស់!!

ក៖ចំ!!

ខ៖អាហ្នឹងឆ្លបហ្នឹងអាកូនហាំ!!

ក៖ ហ្នឹងកូន ឆ្លបកូន។

ខះលោកកូនឆ្លប!!

កះ តាមពិតវាអត់ដឹងអត់អីអ៊ីចឹងណាស់!!

ខះ វាអត់ដឹងខ្យល់ ចុះតាមគេបង្វក់បើញ៉មនិយាយទៅ
បើសម្ដេចតាគាត់ក៏មិនសូវនេះដែរណាស់ មិនសូវដឹងអីដែរតាមតែគេក្រោមៗនេះហាំ!!

កះហ៊ីៗ!!

ខះ បើគិតទៅមិននេះទេមិនអើយឆ្លើយថាគាត់នេះទេ  មិនមែនខុសតែគាត់ទេណាស់
ដីខ្មែរយើងបើមិនសម្ដេចបើគ្រប់គ្រងតែខ្មែរហើយនឹងខ្មែរវាអត់អីទេ
ច្រើនតែអ្នកគេចង់បានអំណាចហ្នឹងចង់តែឡើងសោយរាជ្យ
មិនដឹងចង់ឡើងសោយរាជ្យទៅខាងណាទេ ម៉ានតែចាស់ទៅស្លាប់ដូចតែគ្នា!!

កះ ហ៊ីញ៉មឆ្ងល់ណាស់ចឹក៏រស់អោយស្រួលទៅ ក៏អំណាចអីក៏ខ្លាំងណាស់ណាម្ល៉េះ!!

ខះ ធ្វើតាមធម្មតាទៅកុំគាបសង្កត់ខ្លាំងពេកទៅ យើងធ្វើមើលហ្ន៎ ដីភ្នំអីខ្មេចខ្ទីអស់ហើយ
ហើយយើងអត់គិតផងហ្នឹង ហើយគិតមើលសុទ្ធតែគេអាក្រក់ ហើយគេណោះក៏គេក៏ល្អមិនដឹង
បំណងថ្ងៃមុខទៅអាក្រក់ក៏មិនដឹងយើងគិតមើលហើយចុះបើសម្ដេចតាគាត់មកស្រួលហើយ
ហ៊ីហើយចុះម៉េចបានគាត់ប្រគល់អោយតាហ៊ុន សែន
!!!!!!ពិបាកណាស់!!!ពិបាកបែកចែកណាស់!!

កះ ហ៊ីមិនដឹងអីគេមីងពិបាកណាស់ នយោបាយគេថានយោបោកហាំ!!

ខះនយោបោក អាហ្នឹងបោកយកដីទៅអស់ហើយ។

កះ ហ្នឹងហើយ តិចទៀតអស់រលីងហើយមីងអើយ!!

ខះ គេរៀប និយាយរួមដើមឈើស្រុកញ៉មអស់ហើយ គេកាប់កុំអោយមូសហាំ!!កុំអោយមូស
កើតមូសច្រើន គេកាប់ចោលអោយអស់តែម្ដងទៅ វវវទុកយូរទៅ ស្មៅដុះកំពស់តាមទៅ
វាមានដើមឈើធំៗទៅវាខ្យល់អីបំាងអ៊ីចឹង!!

កះ ហ្ន៎អ្នកមីងនិយាយមកសុទ្ធតែបង្កប់អត្ថន័យ
អ្នកដឹងបានដឹង!!មិញមីងម៉ែមីងនៅក្នុងជំនាន់ប៉ុល ពតហ្នឹងអត់អីម៉ាន់ណាដែរមីងហី?

ខ៖ ម៉ែអត់អីទេ ជំនាន់អាពតហ្នឹងហ្ន៎!!!

ក៖ គេអត់នាំអោយគាត់ទៅណាទៅណីអីណាហី?

ខ៖ អត់!!ទេ គាត់មើលតែកូនខ្ញុំគាត់ហ្នឹង។

ក៖ ហោងហើយអ៊ីចឹង!!

ខ៖ បានតែគាត់ ហ្ន៎គាត់ឆ្លងទន្លេហ៊ីញ៉ុមមើលគាត់ទៅរក
ចុះយើងនៅតូចដែរគេចេះតែបណ្តោយសិនទៅព្រោះអីមានតែម្តាយនោះដល់ហើយចេះតែទៅ
ហើយ ចេះតែទៅតាមគេតាមឯងអ៊ីចឹងទៅបានយកមកអោយគាត់ហូប
ដល់ប្អូនញ៉ុមរាងចេះដើរមួយឆ្នាំហើយ ដល់តែមួយឆ្នាំហ្នឹងចាប់ដេកពេទ្យរហូត។

ក៖ហ៊ឺ!!

ខ៖ទាល់តែបែកទៅយកម៉ែនៅមន្ទីរពេទ្យទេ។

ក៖ហ៊ឺៗ!

ខ៖ បីមក ប្អូនហ្នឹងបីមក!

ក៖ ហើយគេអត់ថាអីដែរ
ភាគច្រើនតែអ្នកណាគេរាងឈឺអីច្រើនពេកហ្នឹងគឺថាគេបង្ហើយតែម្តង!!តែហោងដែរហ្នឹងមីង!!!

ខ៖គេរករៀប ញ៉ុមថាម៉ែកុំយក ប្រយត្ន័គេធ្វើបាបប្អូនញ៉ុម។

ក៖ហ្ន៎អ៊ីចឹងគេរករៀបអោយ!!

ខ៖ រករៀបអោយម៉ែមានគ្រួសារ!!

ក៖
មានប្តី!!ចា៎!!តែប្អូនឈឺនោះក៏គេអត់បង្ហើយដែរមីងណោះ?របៀបថាបង្ហើយអញ្ចេកសម្លាប់ទៅម៉
ងអ៊ីចឹងទៅម៉ងហា៎!!

ខ៖ហ្នឹងហើយ!!

កះដោយសារប៉ុនឈឺពេក!!

ខះ ប៉ុនឈឺប៉ុនអីហេ!!ប៉ុន្តែគេអានិត!!

កះចាំ!!

ខះ ឃើញញ៉ុមតែម្នាក់ឯង!!

កះ ហ្អំដោយសារពេលខ្លះនៅចំជាមួយអ្នកចិត្តធម៌អ៊ីចឹងហ្នឹងណោះមីងណោះ?

ខះ ហ្នឹងហើយអ្នកចិត្តធម៌។

កះចាំ!!

ខះ ព្រោះអីយើងគេហៅជំលៀសចាស់!!

កះហ្អំ!!

ខះ នៅខាងនេះអត់មានជំលៀសថ្មីទេ!!ជំលៀសថ្មីដូចញ៉ុមហើយម្ដាយ
ដូចគ្នាទៅណេះគេដាក់ជំលៀសថ្មីក៏គេបញ្ជូនឡើងឡានដែរទៅបាត់ដំបងពោធិ៍សាត់អីអស់
ហើយ!!

កះអ៊ីចឹងអ្នកថ្មីៗសុទ្ធតែវេទនាទាំងអស់?

ខះ ហ្នឹងហើយ!!!ទៅពោធិ៍សាត់ នេះអត់មានទេ នេះសុទ្ធតែសុទ្ធម៉ង!!
សុទ្ធតែជំលៀសចាស់តស៊ូទៅសំប៉ាន!!

កះ មីងដែលស្គាល់បងប្អូនអ្នកជិតខាងណាឡើងធ្វើជាពួកឆ្លបពួកអីទេ?

ខះ ហ៊ីមើលញ៉ុមរកនឹកសិន!!ហ្អំអត់ទេ មានតែគេយកទៅវ៉ាយដំបង្ខំចិត្ត។

កះ ហ្អំអោយធ្វើ?

ខះ ទ្រាញ៉ុមវិញគេលួចមាន់យកមកអោយហូបដែរប៉ុន្តែប្រហែលជាហូបតិចទេមើលទៅ
ទៅរាយការណ៍មានអីអូសទឹកនោមរហូតតាំងពី៧៥(១៩៧៥)មករហូតទាល់តែបែកទ្រាញ៉ុម
ហើយមីងញ៉ុមអត់អីទេ!!ស្ងួង តិចៗគេហៅទៅស្ងួងដក។

កៈចាំ!ហើយមីងការហូបចុកមីងម៉េចដែរនៅក្នុងជំនាន់ប៉ុល ពត?

ខៈ ការហូបចុកញ៉ុមធម្មតា ពីព្រោះអត់មានអីអត់នេះ អត់មានសូវអត់ដូចគេផ្តាច់ដូចព្ទនៅខាងពោធិ៍សាត់មាននិយាយថាសុទ្ធតែពោតអីៗហូបចុកហូបបាយនៅក្នុងការដ្ឋានដល់គេដាំស្លរឆ្អិនហ្នឹងយើងទៅក្នុងការដ្ឋានហ្នឹងទៅអារប្អូនទៅទៅ
ហើយហូបហើយយកប្អូនទៅផ្ទះទៅម៉ែ!!

កៈ អីចឹងគ្រាន់បើហើយមីងសំណាងហើយមីងអញ្ចឹងណាស់!!សុទ្ធអត់សូវពិបាកទេ
ផ្លែចេកផ្លែអីពេញអីចឹងទៅ!!

កៈ បេះហូបបាន?

ខៈ
ហូបបាន!!ជួនកាលម៉ែទៅសំរានពេទ្យអញ្ចឹងទៅយកសុំបាយកន្លែងការដ្ឋានហ្នឹងយកទៅអោយគាត់!!

កៈ ហ៊ីបានទៀត!!

ខៈ ហ្នឹងហើយ!!

កៈ អ្នកខ្លះអត់ម៉ងមីងណាស់!!

ខៈ ខ្លះអត់មែន
ចំណាស់ញ៉ុមហើយបានចេកក្មេងៗពួកញ៉ុមហ្នឹងអាខ្លះគេអត់ស៊ី!ញ៉ុមអត់ទេនឹកឃើញអត់ស៊ីយកទៅដាក់នៅលើដំបូលដល់តែក្រៀមវិចយកទៅអោយម៉ែនៅហ្នឹងពេទ្យ!!

កៈ អីយ៉ាស់ចេះទៀត!!

ខៈ យកចេញពីហូបបាយហើយ
ជួនកាលទៅដេកជាមួយម៉ែនៅមន្ទីរពេទ្យដើរទៅឃើញចេកអំបូងចេកអីកាត់៥
៥អីចឹងវិចយកទៅអោយម៉ែស្អែកមួយស្ទងហ្នឹងអស់ស្អែករកមួយស្ទងទៀត!!

កៈ អីយ៉ាស់ហោងហើយ!!

ខះ នឹកឃើញដល់ម៉ែ។

កះ ហ្អំមីងសំណាងជាងគេហើយអ៊ីចឹង
!!ហើយមីងដល់ពេលចូលដល់ថ្ងៃចុងក្រោយពេលដឹងថាយួនចូលមករំដោះម៉េចដែរមីង?

ខះ ហ៊ីវៀតណាមចូលមកគេអោយរត់ ភ័យទៅរកម៉ែ ម៉ែចេញមកមុន
ទៅជួបអាឆ្កែចចកគេចិញ្ចឹមនៅកន្លែងមន្ទីរពេទ្យនោះយំជិតងាប់ហើយ!!

កះ ខ្លាចវាខាំហេ?

ខះ ខ្លាចវាខាំមក
គេប្រលេង!!ណោះអានិតកូនមួយនោះម៉ែឪវាគេយកទៅវ៉ៃចោលហាំ!!ហើយគ្នាដើរអត់រួចហាំ
អត់មានម្តាយនៅគ្រប់គ្រងនោះ នៅតែអូសគូទ គេលើកបោះចោលទៅនឹងទន្លេ។

កះ ហើយអត់ទាន់ងាប់ផង?

ខះ មានណាគ្នានៅអង្គុលគូទហ្នឹង អាណាមានអីអោយស៊ីស៊ីទៅ
ជូនណាលហ្នឹងមន្ទីរពេទ្យហ្នឹងគេដាក់បាយអោយស៊ីអ៊ីចឹងទៅស៊ីខ្លួនឯងទៅ អត់ចេះដើរ
ពីព្រោះអត់មានម៉ែណាគ្រប់គ្រងមិនចេះតែបណ្តោយៗអត់ចេះងើបឈរអង្គុលទៅ។

កះហ៊ីៗ!!

ខះ ដល់ហើយ ថាមិនយកគ្នាទៅណាទៅ ទុកចោលហ្នឹងហីទៅ
លោពីណាចិត្តធម៌អីគ្នាយកទៅចិញ្ចឹម នេះអត់បោះគ្នាក្នុងទន្លេម៉ង!!

កះ ហ៊ីពួកអាណាក៏អាក្រក់ម្ល៉េះ!!

ខះ ពួកអានេះហ្នឹង ពួកប្រធានគេហ្នឹង ប្រធានមន្ទីរពេទ្យ មិនមែនថាហ្អំ!!!
មានកន្លែងណាគេចិត្តល្អគេចិត្តល្អ!! ម៉ែគ្នាឪគ្នា
គ្រាន់តែគោស៊ីស្វាយនៅលើទំនប់ទួលក្រសាំងនេះ។

កះហ៊ីៗ!!

ខះ យកម៉ែហើយឪយកទៅវ៉ៃចោលទុកកូនតូចគ្នាទឹមតែបានកូនមួយហ្នឹង។

កៈ ហ៊ុៗ!! អ៊ីចឹងមីងបន្ទាប់ពីបែកប៉ុលពតមកមីងរកស៊ីអីវ៉ាន់ដែរជាមួយម៉ែហ្នឹង ?

ខៈ ហ៊ុបេះតែត្រកួនហ្នឹង។

កៈ ហើយអត់ដែលមានចង់ផ្លាស់ប្ដូរមុខរបរអីគេទេហោ?

ខៈ បេះត្រកួន ទៅនៅជាមួយយាយនៅភ្នំពេញ ស៊ីឈ្នួលគាត់ហ្នឹងមកវិញមានគ្រួសារហ្នឹង!!

កៈ ចាំ!!ហើយចុះពេលមានគ្រួសារមកមីងរកស៊ីអីខ្លះជាមួយពូដែរ?

ខៈរកត្រីម្ដង!!

កៈ រកត្រីម្ដងហោ?!!

ខៈ ហ្នឹងហើយរហូតមកទល់តែឥឡូវ។

កៈចាំ!!

ខៈ
ប៉ុន្តែពិបាកណាស់អូនអើយរកត្រីឥឡូវហ្នំ!!មិនមែនដូចចាស់ៗពីដើមថារកត្រីអីនេះណា!!ញ៉ុម
ឃើញអំញ៉ុមអ្នករកត្រីតាំងពីសង្គមរហូតទាល់តែគាត់ស្លាប់វិញគាត់អត់ទាន់មានមួយជីមួយហ៊ុ
នអីអោយកូនទេ ផ្ទះនៅតែហ្នឹង ត្រូកៗនៅតែហ្នឹង
អ៊ីចឹងបានញ៉ុមមានកូនទៀតគ្រប់កូនទាំងអស់ញ៉ុមអត់អោយរកទេកូន
ម៉ែឆ្អែតឆ្អល់ហើយទូលត្រី ទូលសឹងតែរាល់ថ្ងៃ
មួយថ្ងៃជូនណាលមានពីរជើងអីណោះ!!ចុះទំរាំតែលក់អស់ដើរពីហ្នឹងទៅដល់កំពង់ដរ
ឥឡូវទៅលែងរួចហើយ ឥឡូវបាននិមល។

កៈចាំ!!

ខៈពីព្រឹកឡើងដាក់កន្ទងទៅទៅវាលក់ទៅ ១០០០០ ២០០០០ អីអ៊ីចឹងទៅគេអោយមក
គេទិញអីគេទិញគ្រឿងគ្រៅអីអោយហើយយើងហ្នឹង
បេះត្រកួនបេះស្លឹកបាសថ្មីទៅយកទៅចាប់ ៥០០អីទៅ ជូនណាល
លក់ហ្នឹងមិនដាច់ទៅដល់តាខ្មៅ។

កៈចាំ!!

ខៈជូនណាលជិះម៉ូតូឌុបមកវិញទៀត!!លក់ត្រីកំផ្លៀយជិះម៉ូតូឌុប ម៉ោង៩ ម៉ោង១០ហ្នុំ!!កៈចាំ!!ខៈ ដូចថា! ម៉ែញ៉ុមបើញ៉ុមលក់មិនដាច់មិនញ៉ុមនៅចាំ!!

កៈ ចាំ!!អ៊ីចឹងអ្នកមីងសំរាប់អ្នកមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខៈ ញ៉ុមស្គមដោយសារអី!!ដោយសារញ៉ុមរើសម្ហូប។

កៈ ម្ហូបដោយសារមិនមែនជំងឺទេ ដោយសាររើសម្ហូបវិញ?

ខៈ ហ្នឹងហើយ ដេកក៏អត់សូវបាន បើម្ហូបចេះ បើត្រីអាំងស្វាយទុំមួយមកហើយ ជូនណាលស្លរបានទឹកពីរបីម៉ាត់មកត្រីអាំងហ្នឹងតិចតួចទៅត្រីជាមួយគេពីរបីម៉ាត់ហើយ បង្អែមគេសាគូរទុកអោយមួយថ្ងៃពីរបីកញ្ចប់គេដាក់ក្លាសេទុកអោយអញ្ចឹងទៅ ដល់ហើយយើងហេរថ្មើរម៉ានហូបថ្មើរហ្នឹងទៅ អាហ្នឹងរៀងមានកំលាំងបន្តិចវិញហើយ បើដេកនៅកន្ទេលអត់បែកញើស ទន់ទៅទន់ទៅ ជូនណាលចេះតែដើរ ដើរទៅផ្ទះគេហ្នឹងទៅទៅកិលកិលទៅបេះផ្ទីអ៊ីចឹងទៅដើរទៅបេះត្រកួនទៅ។

កៈ ហើយផ្ទីហ្នឹងដើរកាត់ហ្នឹងវាដុះខ្លួនវាហេ?

ខៈ ដុះខ្លួនឯងនោះចំការគាត់ញ៉ុមបេះរាល់តែឆ្នាំ!!

កៈ គាត់អោយកាត់ដែរហេ?

ខៈ បេះរាល់តែថ្ងៃ !!ហ៊ីមានតែស្លឹកអំពិលគាត់ហ្នឹង ហ៊ីម៉ែអើយស្លឹកអំពិលហ៊ា!! មើលតែគេថាទុកស្លរ មីងមីងឯងមួយដៃស្លរ !!ស្លរអី !គេថាស្លរប្រហើរ អ៊ិចឹងញ៉ុមទុកខាងណោះអោយស្លរទៅ ឆ្នាំមុន ជូនណាលញ៉ុមកាប់បានជូនណាល៥០ គីឡូ ២០ គីឡូ ៣០គីឡូ។

កៈ ស្លឹកអំពិល?

ខៈ មិនមែនទេ!!

កៈ ផ្ទី?

ខ៖ ផ្ទី ជូនកាលស្លឹកបាស់ ៤ ១០ ២០ដុំអ៊ីចឹងទៅអោយនិមល
ជូនកាលបោះអោយគេនៅមុននេះអ៊ីចឹងទៅ។

ក៖ ហើយចុះអត់ព្រមដាំនៅពទ្ធ័ជុំវិញផ្ទះទៅអត់ទេហោ?

ខ៖ឡើកមុនដាក់តើ ដីគេនេះជូនណាលដាក់ល្មៅដាក់ដាំទៅ ដាំទៅកាត់លក់៥ទងអី១០០០
ចេះតែអោយទៅ យើងចាស់ហើយយើងធ្វើអីកើត!!

ក៖ សុំដីគេដាំទៅ បើគេត្រូវការធ្វើអោយគេទៅ?

ខ៖ សុំដីគេដាំហើយ ប៉ុន្តែគេថាអញ្ចេក គេខ្លាចដល់គេលក់ទៅយើងនៅជំនាំ
ញ៉ុមថាបើជំនាំយហ្នឹងយកវិញ!!ហាចង់លក់ប្រាប់ញ៉ុមទៅញ៉ុមកាត់យកទៅ គាត់ថាអត់ទេ
ខ្លាចគេនេះហា៎!គាត់!!

ក៖ គ្រាន់តែអញ្ចឹងសោះចិត្តអាក្រក់ម្ល៉េះទុកដីចោល!!

ខ៖ បើនិយាយទៅលឺគេផ្សាយថាតែម្ចាស់
យើងអ្នកថៃហ្នឹងតែ៣ឆ្នាំគឺដាច់លើយើងម្ល៉ោះហើយគេអត់ហ៊ានអោយទេ!!ញ៉ុមថាប៉ុនអត់ទេ!

ក៖តែប្លង់នៅលើម្ចាស់របស់ម្ចាស់ហើយ!!

ខ៖ បើញ៉ុមដើមអំពិលដើមអីហ្នឹង ញ៉ុមបេះជូនណាលស្លឹកបាស់ដុះហ្នឹងញ៉ុមបេះ
ជូនណាលពួកហ្នឹងនៅជិតហ្នឹងអត់ហ៊ានអោយគោស៊ីទេថាទុកអោយបងបេះ។

ក៖ ចា៎ចិត្តល្អណាស់អ៊ីចឹង។

ខ៖ ហេញ៉ុមនៅនេះមិនដែលមានសត្រូវទេ!!

ក៖ ចា៎ល្អហើយអញ្ចឹងមីង!!មីងអ៊ីចឹងសំរាប់ក្ដីសង្ឃឹមទៅថ្ងៃក្រោយម៉េចដែរ?

ខ៖
ហ៊ីសង្ឃឹមទៅថ្ងៃក្រោយទៅអនាគតកូនញ៉ុមបានធ្វើការងារធំដុំទៅគេថាលោះយើងចាស់ទៅ
ណោះអោយមួយបន្តិចណោះគេអោយបន្តិចអីបានរួចខ្លួន។

ក៖ ឥឡូវអត់មានឈឺអីគេណាហី?

ខ៖ អត់!!

ក៖ ស្គមហ្នឹងដោយសាររឿងរើសម្ហូបទេអីចឹងហោ?

ខ៖ តែម្ហូបទេ!!ហើយដេកអត់លក់ អញ្ចេកដេកហ្នឹងអញ្ចេក ដេកហ្នឹងនឹកឃើញហ៊ីអាមួយនៅណោះអាមួយនេះព្រឹកឡើងមិនដឹងថាបានលុយទៅខាងណាខាងណីទេហោ!!បានមួយពេលគិតមួយពេល លុយយើងគិត អង្ករយើងអត់សូវគិតទេណាស់រឿងម៉ាហូបចុកខ្លួនយើងអត់គិតទេខ្លាចព្រឹកឡើងដើរខ្ចីគេអោយកូនធ្វើការអីងាប់ហើយ អីចឹងបានត្រុងៗទៅ។

ក៖ចេះតែខំទៅ។

ខ៖ ណោះអាណោះ ៥០០០អានេះ២០០០ ៣០០០ទៅបាន២នាក់ហើយ អីចឹងដល់នេះទៅឪបានត្រឹមក ហ៊ីអានេះបានមួយនាក់ទៀតហើយ រួចខ្លួនធូរទ្រូងទៀតទៅ។

ក៖ អីចឹងមួយថ្ងៃមួយថ្ងៃ!!

ខ៖ បើអីចឹងអ់តទេហ្មើយដេកអត់លក់ទេ គ្រាន់ចិត្តចង់ធ្វើផ្ទះហ្នឹងហាំ!! ហ្មើយដេកគិតហ៊ីមិនដឹងទិញអាណាមុនទេគិត ហើយគ្មានបានប៉ុន្មានបានតែ១០០ហ្នឹង១០០ជាង ១២០ហ្នឹងទៅរកអញ្ចឹងទៅអោយលុយគេធ្វើការគេបើកមកធ្វើខ្លួនយើងទៅ។

ក៖ចាំ!!

ខ៖ ខ្ចីលុយរដ្ឋ១០០០០០០យកមកទិញបណ្ដុះម្ដងបន្តិចម្ដងបន្តិចទំរាំរួច!!

ក៖ ចាំ!!អញ្ចឹងមីងមួយនេះគឺជាសំនួរមួយចុងក្រោយ ហោដល់វគ្គបញ្ចប់ហើយ អ្នកមីងបានរៀបរាប់ពីជីវិតបានក្បោះក្បាយខ្លាំងមែនទែន អីចឹងអ្នកមីងសំរាប់ដំបូន្មានចុងក្រោយដែលអ្នកមីអចង់ទូរន្មានកូនហាំ ចង់ទូរន្មានកូនម៉េចដែរ?ថាផ្ដែផ្ដាំម៉េចដែរ អោយដើរផ្លូវម៉េចអីចឹងទៅណាស់?

ខ៖ ញ៉ុមចង់អោយកូនញ៉ុមល្អ កុំអោយដូចឃើញដូចកូនគេដូចគ្រប់គ្នា ញ៉ុមគ្រាន់តែឃើញកូនគេគ្រប់គ្នាធ្លាក់ដើរលេងដើរអី ដើរជក់ដើរអីអីចឹងៗញ៉ុមទូចចិត្តណាស់

ប៉ុន្តែញ៉ុមគ្រាន់តែទូចចិត្តជំនួសគេទេណាស់ប៉ុន្តែបើក្នុងផ្ទះកូនចៅញ៉ុមអត់តូចចិត្តទេ
ញ៉ុមអាចសង្ឃឹមថាបានកូនញ៉ុម១០០%ម៉ងថ្ងៃក្រោយ។កះចាំ!ខះ
បើថាញ៉ុមឃើញបងជីដូនមួយរបស់ញ៉ុមបងបងជីដូនមួយជាមួយញ៉ុមគ្រប់គ្នា
អាមួយអញ្ចេះអាមួយអញ្ចុះ ហើយញ៉ុមឃើញអញ្ចឹងអត់ទេ
ហើយញ៉ុមប្រដៅកូនញ៉ុមរាល់ថ្ងៃថាកូនល្ងើយកូនឯងអានិតម្ដាយណាស់
ម្ដាយខំប្រឹងបេះត្រកួនខំប្រឹងបេះអី
ដល់ពេលកូនឯងដើរភ្លើតភ្លើនទៅកូនឯងចុះគេចាប់បានចុះកូនឯងគេចាប់ដាក់គុកដាក់អីទៅ
តើម៉ែមានចិត្តអានិតអាសូរកូនឯង!!ហើយម៉ែខ្មាស់គេទៅអើតមើលកូនឯងនៅក្នុងគុក
មុខមាត់កូនឯងប៉ុណ្ណឹងដែរ ដល់កូនឯងចូលគុកទៅតើកូនឯងខ្មាស់!!

កះ វាពិបាកទៀតហ្នឹងមីងហាំ!!

ខះ ហ្នឹងហើយ !!

កះ ពិបាកខ្លួនឯងហ្នឹងទៀតណាស់!!

ខះ អាពិបាកខ្លួនឯងខ្លាំងជាងគេដេកស្រួលនោះ ក្នុងគុកដេកស្រួលទៅមិនដឹង?

កះ ស្រួលណាទេស្រួលទាល់តែមានលុយដែរ គ្រាន់តែអត់មានសេរីភាព
យើងចង់ដើរហើរទៅណាអត់បានទេ!!

កះ មើលមិនដូចអាសីហាហ្នឹង ៣ ៤ឆ្នាំហើយ !!នៅប៉ុន្មាននៅ១២ឆ្នាំ
ហើយកូនពោះធំតាំងពីបាន៣ខែរហូតកូនចេះដើរហើយអត់ទាន់ឃើញមុខកូនផង!!

កះ ចឹជាប់គុក!!

ខះ ឪពុកលក់ម៉ាកូនលក់ថ្នាំ។

កះ អ្នកណាគេកូនប្រសារហើអី?

ខះ មិនមែនទេ!!

កះ អ្នកណាគេ?

ខ៖ ឈ្មោះអាសីហានៅផ្ទះនៅព្រែកនោះ ពួកមាត់ព្រែកសុទ្ធតែជក់!!

ក៖ ជក់សាហាវម៉ងមីងណោះ?

ខ៖ ហ៊ីទាំងអស់ហ្នឹង។

ក៖ ហ្នឹងហើយ។

ខ៖ ក្នុងភូមិហ្នឹង!!!

ក៖ គេប្រាប់ហើយបើសិនជាជក់ ជួញដូរគ្រឿងញៀនវាត្រូវជាប់គុកហើយ
ហើយតែដល់ពេលអត់ស្តាប់ប្រឹងប្រព្រឹត្តិទៀត!!

ខ៖ ថ្ងៃមុននោះអើរ
ប៉ុនតូចៗថាល្មមយើងឥឡូវក្មេងអាយុយ៉ាងច្រើនជាង១០ឆ្នាំគេជក់វាផឹកវាស៊ីអីចឹងទៅ
វាអត់អានិតជីវិតម្តាយហើយវាអត់អានិតជីវិតវាហើយវាអត់អានិតទៅថ្ងៃមុខថ្ងៃអីទៅអត់!!អីចឹង
បានញ៉ុមចេះតែណែនាំកូនអើយអាមួយនោះចង់ទៅប្រដាល់ ញ៉ុមថាកូនឈឺសាច់ណាស់
សុខចិត្តអោយកូនឯងទៅធ្វើម៉ូតូពីព្រោះអីធម្មតាក៏គេត្រូវការដៃរខាងប្រដាល់ខាងអីប៉ុន្តែម៉ែខំប
ង្កើតកូនឯងមកវារ៉ៃម៉ែស្តាយដៃអានិតកូន
ហើយដល់កូនឯងទៅអីចឹងអោយគេរ៉ៃអានិតកូនកុំអីកូន គ្នាតាមក៏ឈប់ទៅទៅធ្វើម៉ូតូទៅ
អាមួយនោះម៉ែញ៉ុមចង់រកត្រី អត់ទេ!!
ចាំមើលម៉ែសួរគេអង្គការគេសួរថាចង់ធ្វើអីធ្វើអីបញ្ជូនអោយទៅធ្វើចុងភៅ
ឥឡូវអើយវារៀនអត់ទាន់ចប់ទេអោយមួយខែ៣០០ មួយខែ៣០០ ប៉ុន្តែអត់ព្រមធ្វើទេ។

ក៖ ចាំរកអាច្រើនទៀតហេ?

ខ៖
ថាចាំបានសញ្ញាបត្រ័សិន!!វាថាម៉ែអើយបើញ៉ុមអត់សញ្ញាបត្រ័ក៏ញ៉ុមទិញម៉ូតូជិះបានដែរហើយ
វាអត់ហ៊ានចង់ចូលផ្ទះទេ!! ហើយមីបងចូលធ្វើការ !!វាប្រុសទេ
!!ញ៉ុមអត់សរសើរទេប៉ុន្តែគ្រាន់តែថា!!

ក៖វារាងមានលំនឹង!!

ខ៖ វារាងចូលគន្លង!!

ក៖ ហ្នឹងហើយ។

ខ៖ ចូលគន្លងអត់មាន!!

ក៖ អីចឹងរាល់ថ្ងៃសង្ឃឹមហ្នឹងគឺកូនហ្នឹងតែម្តង!!

ខ៖ អាមួយនោះកាលលើកមុនហូ!!ពេលែរ
ញ៉ុមចេះតែលួងៗកូនអើយកូនឯងរកត្រីម៉ែមានទូកមានក្តារកូនឯងទៅនៅបឹងហែលពោងហ្នឹង
អានិតកូនណាស់
ឃើញកូនហែលខ្វីៗៗហ្នឹងខ្លោចចិត្តលួងលួងចេះដើរសួរគេសួរឯងគេអោយទៅរៀបឆាកទៅ
ទៅទៅកូន អាឪនិយាយឈប់រកឈប់អីទៅមិនមែនដូចណោះទេ
មិនមែនដូចឪពុកទេកូនឪពុកឆ្អែតឆ្អល់ហើយរកទំរាំបានផ្ទះនៅប៉ុណ្ណឹង
កូនឯងទៅរកកន្លែងណាដែលវាមានថ្លៃថ្នូរកុំអោថោកទាបហើយធ្វើម៉េចកុំអោយទៅដើរផ្លូវខុស
ឆក់ ប្លន់ លួចគេ មិនហ៊ានទេ!! កាលលើកមុនកាលពីទឹមចូលវិហារដំបូង
ហ្អើយថ្ងៃណាក៏ចង់ទៅដែរ គ្រាន់តែនេះប្រពន្ធគេម៉ែម៉ែងឯងអត់ទៅវិហារ
ចាំអញធ្វើផ្ទះអញហើយសិនបានអញទៅ អញអត់ភ្លេចទេវិហារហ្ហ៎!!

ក៖ចាំពួកយើងរងចាំអ្នកមីងវិញ!!ព្រះនៅតែចាំអ្នកមីងរហូត។

ខ៖ ញ៉ុមកុំអោយតែវិហារ ហ៊ីវិហាររត់ចោលញ៉ុមម្តងដែរតើ!!!

ក៖ ចីបានរត់ចោលវិញ?

ខ៖ ណោះនៅជិតតាខ្មៅណោះ!!នៅជិតពេទ្យជ័យជំនះហ្ហ៎!!

ក៖ហ្នឹងហើយ ហ្នឹងហើយ!!

ខ៖ មិនរត់មកណោះ!! អត់ដឹង មុំង៉ែងជូនអញទៅវិហារតិចមក!!ហោថាម៉ែញ៉ុមទៅមុន
ដល់វាទៅមុន!!

ក៖ អត់ដឹងថាដូរហោ?

ខះ អត់ដឹងថាដូរផងហ្នឹងញ៉ុមថា ហ៊ីវិហាររត់ចោលញ៉ុមមែន ញ៉ុមអត់រត់ចោលវិហារសោះ!!

កះចាំអញ្ជឹងមីងមានអីចង់និយាយបន្ថែមទៀតអីអត់?ពីអី!!

ខះ ហ៊ុបានហើយ!!

កះ
តែប៉ុណ្ណឹងទេហោអ៊ីចឹងហោ!!ចាំ!!អ៊ីចឹងអរគុណអ្នកមីងសំរាប់ថ្ងៃនេះសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយដែលអ្នកមីងបានរៀបរាប់ប្រាប់ចង់អោយកូនចៅក៏ដូចជាមនុស្សជំនាន់ក្រោយបានដឹងពីប្រវត្តិរបស់អ្នកមីងហាំអ្នកមីង ចាំអ៊ីចឹងអរគុណច្រើនណាស់អ្នកមីង!!

ខះ ចាំ។